អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ឱ្យស្វែងរកលទ្ធភាពបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ហើយច្រានចោលបណ្តឹងសាទុក្ខប្រឆាំងនឹងវិសាលភាពនៃសំណុំរឿង ០០២/០១

នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចេញសេចក្តីសង្ខេបនៃសេចក្តីសម្រេចរបស់ខ្លួនស្តីពីបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា និង នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចទីពីររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបំបែកសំណុំរឿង ០០២ ទៅជាការជំនុំជម្រះជាបន្តបន្ទាប់ដាច់ដោយឡែកពីគ្នា។

ទោះបីជាបដិសេធបណ្តឹងសាទុក្ខលើអង្គសេចក្តីក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលចេញចំណាត់ការកែតម្រូវ និងបង្គាប់ថា សវនាការលើភស្តុតាងក្នុងការជំនុំជម្រះទីពីរ (សំណុំរឿង ០០២/០២) ត្រូវតែចាប់ផ្តើមឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ក្រោយពីកិច្ចបិទការពិភាក្សាដេញដោលនៅក្នុងការជំនុំជម្រះនាពេលបច្ចុប្បន្នក្នុងសំណុំរឿង ០០២/០១។ លើសពីនេះទៀត អង្គជំនុំជម្រះបង្គាប់ថា សំណុំរឿង ០០២/០២ ត្រូវបញ្ចូលជាអប្បបរមានូវបទចោទទាក់ទងទៅនឹង ស-២១, ការដ្ឋានធ្វើការ សហករណ៍ និងបទចោទប្រល័យពូជសាសន៍។ អង្គជំនុំជម្រះថែមទាំងបានបង្គាប់ឲ្យការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ស្វែងរកលទ្ធភាពក្នុងការបង្កើតនៅក្នុងអង្គជំនុំជម្រះសាលាដំបូងដដែលនូវក្រុមប្រឹក្សាជំនុំជម្រះទីពីរ ដែលមានចៅក្រមជាតិនិងអន្តរជាតិ ដើម្បីស្តាប់ និងជំនុំជម្រះលើសំណុំរឿង ០០២/០២។

អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះជាបានផ្តល់នូវការពិចារណាសមស្របទៅលើភាពជាតំណាងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ ទៅជាការជំនុំជម្រះតូចៗយ៉ាងណាក៏ដោយ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងមិនគោរពតាមការបង្គាប់របស់ខ្លួន ស្តីពីការបង្កើតផែនការជាក់លាក់មួយសម្រាប់ការជំនុំជម្រះទៅលើបទចោទទាំងអស់ គឺជាកំហុសផ្នែកអង្គច្បាប់ និងកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន។

អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបដិសេធក្នុងការកែប្រែគោលជំហរពីដំបូងរបស់ខ្លួនលើការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងការសម្របសម្រួលទៅតាមសំណើរបស់ភាគី និងដោះស្រាយក្តីបារម្ភណាមួយរបស់ភាគីដែលជាបច្ច័យនៃការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មីសម្រាប់ការជំនុំជម្រះនាពេលអនាគត ហើយថា នេះបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូង ប្រហែលជាពុំបានរៀបចំក្នុងការជំនុំជម្រះបទចោទដែលនៅសេសសល់នៅក្នុងដីកាដំណោះស្រាយនៅក្នុងការជំនុំជម្រះបច្ចុប្បន្នឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅក្នុងកាលៈទេសៈបច្ចុប្បន្ន ការបង្គាប់ឱ្យពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ និងតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងកែប្រែផែនការរបស់ខ្លួន នឹងបណ្តាលឱ្យមានការពន្យារពេល ដែលឥតចាំបាច់។

អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ចំណាត់ការសមស្របក្នុងកាលៈទេសៈបច្ចុប្បន្ន គឺត្រូវបង្គាប់ថា បទចោទដែលមិនបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នឹងក្លាយជាវិសាលភាពនៃសំណុំរឿង ០០២/០២ ដើម្បីធានាថា ការបូកបញ្ចូលគ្នានៃសំណុំរឿង ០០២/០១ និង ០០២/០២ នឹងក្លាយជាភាពតំណាងសមស្របនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០២។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សំណុំរឿង ០០២/០២ ត្រូវតែចាប់ផ្តើមឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន និងថា ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរដើម្បីសម្រេចលើបញ្ហានេះ នាពេលបច្ចុប្បន្ន បានក្លាយជាបញ្ហាសំខាន់។

ជនជាប់ចោទដែលទទួលការជំនុំជម្រះក្នុងសំណុំរឿង ០០២ គឺ នួន ជា ដែលជាអនុលេខានៃបក្សកុម្មុយនីសកម្ពុជា និង ខៀវ សំផន ដែលជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះសាលាដំបូង ជាដំបូង បានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើបទចោទ ក្នុងសំណុំរឿង ០០២ ទៅជាការជំនុំជម្រះតូចៗដាច់ដោយឡែកពីគ្នា ដែលសំណុំរឿងលើកទីមួយ ០០២/០១ កំពុងដំណើរការ។ ក្រោយពីទទួលបានបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងវិសាលភាពនៃបទចោទក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ បានមោឃៈដីកាបំបែកលើកដំបូងរបស់អង្គជំនុំជម្រះសាលាដំបូង។ បន្ទាប់ស្តាប់នូវទស្សនៈរបស់ភាគី អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីជាថ្មី នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ដោយរក្សាទុកនូវវិសាលភាពនៃការជំនុំជម្រះដដែល នៅក្នុងសំណុំរឿង ០០២/០១ ដូចកាលពីមុន មុនពេលអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចមោឃភាព។ លទ្ធផលនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខចេញថ្ងៃនេះ ដោយដម្កល់វិសាលភាពនៃបទចោទក្នុងសំណុំរឿង ០០២/០១ គឺថា បទចោទទាំងនេះ កម្រិតត្រឹមតែ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងនឹងការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៧៥ ដំណាក់កាលទីពីរនៃការជម្លៀសដែលបានចាប់ផ្តើមក្នុងខែកញ្ញា ឆ្នាំ១៩៧៥ និងការសម្លាប់លើទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ក្នុងខេត្តពោធិ៍សាត់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**

មន្ត្រីទំនាក់ទំនងផ្នែកច្បាប់

ទូរស័ព្ទដៃ: +៨៥៥(០)១២ ៤៨៨ ០២៣

ទូរស័ព្ទ: +៨៥៥ (០)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩

សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**

មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម

ទូរស័ព្ទដៃ: +៨៥៥ (០)១២ ៤៨៨ ១៥៦

សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh